# ទិដ្ឋាការចេញចូលមួយដង គោលបំណងពាណិជ្ជកម្ម

(កិច្ចប្រជុំ សន្និសិទ ការបណ្តុះបណ្តាលជំនាញបន្ថែមដោយមិនទទួលបានប្រាក់ចំនួល ការផ្លាស់ប្តូរវប្បធម៌ កីឡា និង កម្មសិក្សាជាដើម)

| | | ឯកសារតម្រូវ | កំណត់ចំណាំ |
|---|---|---|---|
| ឯកសារត្រូវរៀបចំដោយសាមីជន | | | |
| ១ | ☐ | លិខិតឆ្លងដែន ច្បាប់ដើម | · មិនមានស្នាមប្រឡាក់ ឬការខូចខាត<br>· ត្រូវមាន២ទំព័រសម្រាប់បិទទិដ្ឋាការ |
| ២ | ☐ | ពាក្យស្នើសុំទិដ្ឋាការ ច្បាប់ដើម<br>*(បិទរូបថត១សន្លឹក)*<br><br>សេចក្តីពន្យល់អំពីការបំពេញពាក្យស្នើសុំ (ខ្មែរ) | · រូបថតបិទកាត (ថតថ្មីក្នុងរយៈពេល៦ខែ)<br>(បណ្តោយ: ៤.៥សង់ទីម៉ែត្រ x ទទឹង: ៣.៥សង់ទីម៉ែត្រ,<br>ផ្ទៃពណ៌ស, រូបថតពណ៌ ឬសខ្មៅ)<br>· បំពេញពាក្យ "N/A" សម្រាប់សំណួរដែលមិនត្រូវនឹងលក្ខខណ្ឌរបស់អ្នក |
| ៣ | ☐ | ឯកសារបញ្ជាក់លទ្ធភាពរ៉ាប់រងលើការចំណាយ | · ករណីនិយោជកធានាលើការចំណាយ<br>- លិខិត ឬឯកសារបញ្ជាក់ពីការធានា<br>- ប៉ាតង់របស់ក្រុមហ៊ុន (ច្បាប់ចម្លង)<br>· ករណីសាមីជនចំណាយដោយខ្លួនឯង សូមដាក់សេចក្តីចម្លងតុល្យបញ្ជីគណនី Bank statements (ធ្វើបច្ចុប្បន្នភាពកំឡុងពេល៣ខែចុងក្រោយមកទល់នឹងថ្ងៃដាក់ពាក្យស្នើទិដ្ឋាការ) |
| ៤ | ☐ | លិខិតបញ្ជាក់ការងារ | · បញ្ជាក់ពីឈ្មោះ មុខដំណែង រយៈពេលធ្វើការងារ ប្រាក់បៀវត្សៗល។ (មិនមានកំណត់ទម្រង់សរសេរ) |
| ៥ | ☐ | លិខិតបញ្ជាបេសកកម្ម | (មិនមានកំណត់ទម្រង់សរសេរ)<br>· អត្ថន័យក្នុងលិខិតត្រូវមានឈ្មោះ តួនាទី គោលបំណង អ្នកធានាលើការចំណាយ។ល។ |
| ឯកសារត្រូវរៀបចំដោយភាគីអញ្ជើញខាងជប៉ុន | | | |
| ៦ | ☐ | លិខិតបញ្ជាក់មូលហេតុនៃការអញ្ជើញ | · មិនតម្រូវអោយមានត្រាទេ<br>· សូមពន្យល់ពី "គោលបំណងអញ្ជើញ" និង "ដើមហេតុនៃការអញ្ជើញ"អោយបានក្បោះក្បាយ។<br>· ករណីអញ្ជើញច្រើនជាងម្នាក់ សូមសរសេរ "ចំនួនបន្ថែមនៅលើលិខិតអញ្ជើញនេះ" និងភ្ជាប់ "បញ្ជីរាយនាមអ្នកដាក់ពាក្យសុំ"។ |

| | | | |
|---|---|---|---|
| ៧ | ☐ | តារាងស្នាក់នៅ/<br>កម្មវិធីបណ្តុះបណ្តាល | · ករណីបេសកកម្ម និង ពាណិជ្ជកម្ម<br>- សរសេរលម្អិតពីសកម្មភាពប្រចាំថ្ងៃ (ចាប់ពីថ្ងៃចូលរហូតដល់ចេញពីប្រទេសជប៉ុន)<br>- គម្រោងថ្ងៃចូលនិង ចេញពីជប៉ុន, ជើងហោះហើរដែលអ្នកគ្រោងជិះ, ឈ្មោះព្រលានសម្រាប់ហោះចូល និងចេញពីប្រទេសជប៉ុន។<br>- បំពេញពត៌មានកន្លែងស្នាក់/សណ្ឋាគារ (ឈ្មោះ, អាស័យដ្ឋាន, លេខទូរស័ព្ទ)<br>· ករណីការបណ្តុះបណ្តាលជំនាញបន្ថែមដោយមិនទទួលបានប្រាក់ចំនូល សូមដាក់ឯកសារទាក់ទងនឹងកម្មវិធីបណ្តុះបណ្តាលទាំងមូល (មានលម្អិតពីវគ្គបណ្តុះបណ្តាល, វិធីសាស្រ្ត, ទីតាំង, រយៈពេល, កាលវិភាគប្រចាំថ្ងៃដែលមានបញ្ចូលទាំងពត៌មានហោះហើរ, អ្នកទទួលបន្ទុក និងភាសាដែលត្រូវប្រើប្រាស់) |
| ឯកសារត្រូវរៀបចំដោយភាគីធានាខាងជប៉ុន (ករណីជប៉ុនធានាថ្លៃចំណាយ) | | | |
| ៨ | ☐ | វិញ្ញាបនប័ត្រចុះបញ្ជីក្រុមហ៊ុន/ស្ថាប័ន ឬប្រវត្តិសង្ខេបរបស់ក្រុមហ៊ុន/ស្ថាប័ន | · មិនតម្រូវចំពោះរដ្ឋាភិបាលជាតិ/មូលដ្ឋាន ឬភ្នាក់ងាររដ្ឋបាលដែលមានសហប្រតិបត្តិការ<br>· វិញ្ញាបនប័ត្រចុះបញ្ជីក្រុមហ៊ុន(Tokibo-Tohon),ខិតប័ណ្ណផ្សព្វផ្សាយក្រុមហ៊ុន, ប្រវត្តិសង្ខេបរបស់ក្រុមហ៊ុន។<br>· ករណីអ្នកអញ្ជើញគឺជាក្រុមហ៊ុនដែលបានចុះបញ្ជីនៅក្នុងផ្សារហ៊ុន អាចដាក់ជំនួសដោយច្បាប់ចម្លងនៃរបាយការណ៍ប្រចាំត្រីមាសចុងក្រោយបំផុត (Shiki-Ho)<br>·ករណីអ្នកអញ្ជើញជាបុគ្គល (មិនមែនក្រុមហ៊ុន ឬអង្គការ) សូមដាក់លិខិតបញ្ជាក់ការងារ ឬអាជ្ញាប័ណ្ណអាជីវកម្មរបស់គាត់។ |
| ៩ | ☐ | លិខិតធានា | · មិនតម្រូវអោយមានត្រាទេ<br>· ករណីអញ្ជើញច្រើនជាងម្នាក់ សូមសរសេរ "ចំនួនបន្ថែមនៅលើលិខិតអញ្ជើញនេះ" និងភ្ជាប់ "បញ្ជីរាយនាមអ្នកដាក់ពាក្យសុំ"។ |